Australian Government
Medicare Australia

PBS

# ការយក និងផ្ញើថ្នាំពេទ្យនៃគំរោងប្រាក់ជំនួយថ្លៃថ្នាំពេទ្យទៅបរទេស

ប្រភេទជាច្រើននៃថ្នាំពេទ្យមានតម្លៃច្រើនជាងតម្លៃដែលលោកអ្នកចំណាយ – ដោយព្រោះថ្នាំខ្លះមានតម្លៃរាប់រយដុល្លារ។ តាមរយៈគំរោងប្រាក់ជំនួយថ្លៃថ្នាំពេទ្យ (Pharmaceutical Benefits Scheme - PBS) រដ្ឋាភិបាលអូស្ត្រាលីជួយចេញថ្លៃសំរាប់ថ្នាំពេទ្យតាមវេជ្ជបញ្ជាមួយចំនួនយ៉ាងធំទូលាយ។

ពលរដ្ឋអូស្ត្រាលីទាំងអស់អាចទិញថ្នាំពេទ្យតាមតម្លៃថោកសមរម្យ តាមរយៈ PBS ។ ថ្នាំពេទ្យ PBS ក៏មានផងដែរសំរាប់ភ្ញៀវមានសិទ្ធិទទួលមកពីប្រទេសអ៊ីតាលី នូវែលហ្សេឡង់ សាធារណរដ្ឋអៀរឡង់ ហ្វាំងឡង់ ន័រវេ ម៉ាល់តាហុល្លង់ ស៊ុយអែដ ប៊ែលជីម និងចក្រភពអង់គ្លេស។ ប្រទេសអូស្ត្រាលីមានកិច្ចព្រមព្រៀងថែទាំសុខភាពទៅវិញទៅមកជាមួយនឹងប្រទេសទាំងនេះ។

ជាការខុសច្បាប់ក្នុងការយក ឬផ្ញើថ្នាំពេទ្យដែលរដ្ឋជួយចេញថ្លៃឲ្យចេញទៅក្រៅប្រទេសអូស្ត្រាលី សំរាប់មូលហេតុក្រៅពីការប្រើដោយផ្ទាល់ខ្លួន ឬការប្រើដោយផ្ទាល់ខ្លួននៃជនណាមួយដែលធ្វើដំណើរចេញពីប្រទេសអូស្ត្រាលីជាមួយលោកអ្នក ឧទាហរណ៍៖ កុមារជាដើម។ ការរឹតត្បិតក៏មានផងដែរលើចំនួនថ្នាំពេទ្យ PBS ដែលលោកអ្នកអាចយក ឬផ្ញើទៅបរទេស។

អ្នកដែលអាជ្ញាធរបានរកឃើញថាយក ឬផ្ញើថ្នាំពេទ្យ PBS សំរាប់ការប្រើប្រាស់ក្រៅអំពីគោលបំណងសមស្រប អាចទទួលការពិន័យជាប្រាក់ដល់ទៅ $5000 និង/ឬជាប់ពន្ធនាគារពីរឆ្នាំ។

## ការយកថ្នាំពេទ្យ PBS ទៅបរទេស

បើលោកអ្នកគ្រោងធ្វើដំណើរទៅបរទេស ជាការសំខាន់ណាស់ដែលលោកអ្នកយកទៅជាមួយនូវថ្នាំពេទ្យតាមវេជ្ជបញ្ជារបស់លោកអ្នក ដើម្បីឲ្យលោកអ្នករក្សាសុខភាពល្អនៅក្នុងពេលនៅបរទេស។ ជាការសំខាន់ផងដែរក្នុងការឆែកមើលថាតើប្រទេសដែលលោកអ្នកនឹងធ្វើដំណើរទៅ ចាត់ទុកថ្នាំពេទ្យរបស់លោកអ្នកជាថ្នាំខុសច្បាប់ឬទេ។

បើលោកអ្នកយកថ្នាំពេទ្យ PBS ទៅបរទេសសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬការប្រើប្រាស់ដោយអ្នកណាមួយដែលធ្វើដំណើរ

ជាមួយលោកអ្នក លោកអ្នកគួរ៖

- និយាយជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក និងពិភាក្សាអំពីថ្នាំពេទ្យដែលលោកអ្នកនឹងត្រូវយកទៅជាមួយលោកអ្នក
- ទាក់ទងស្ថានទូតនៃប្រទេសដែលលោកអ្នកនឹងអញ្ជើញទៅ ដើម្បីធានាថាថ្នាំពេទ្យនេះមានភាពស្របច្បាប់នៅទីនោះ
- កាន់លិខិតមួយច្បាប់ពីវេជ្ជបណ្ឌិតលោកអ្នកដែលបញ្ជាក់នូវគោលបំណងនៃថ្នាំពេទ្យនេះ ចំនួនដែលលោកអ្នកយកទៅជាមួយ ហើយបញ្ជាក់ថាថ្នាំពេទ្យនោះគឺសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនលោកអ្នក
- ទុកថ្នាំពេទ្យនេះនៅក្នុងកញ្ចប់ដើមរបស់វា ដើម្បីបង្ហាញយ៉ាងច្បាស់នូវផ្លាកដែលមានឈ្មោះរបស់លោកអ្នក និងការណែនាំអំពីកម្រិតប្រើ។

## ការផ្ញើថ្នាំពេទ្យ PBS ទៅបរទេស

បើលោកអ្នកគ្រោងផ្ញើថ្នាំពេទ្យ PBS ទៅបរទេសសំរាប់ការប្រើប្រាស់របស់លោកអ្នកផ្ទាល់ខ្លួននៅពេលស្នាក់នៅបរទេស ឬសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់ជនណាមួយទៀតដែលធ្វើដំណើរចេញពីប្រទេសអូស្ត្រាលីជាមួយលោកអ្នក លោកអ្នកគប្បី៖

- និយាយជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក និងពិភាក្សាអំពីថ្នាំពេទ្យដែលលោកអ្នកនឹងត្រូវផ្ញើ

- ទាក់ទងស្ថានទូតនៃប្រទេសដែលលោកអ្នកនឹងអញ្ជើញទៅ ដើម្បីប្រាកដឲ្យបានច្បាស់ថាថ្នាំពេទ្យនេះមានភាពស្របច្បាប់នៅទីនោះ
- ភ្ជាប់នូវលិខិតមួយច្បាប់ពីវេជ្ជបណ្ឌិតរបស់លោកអ្នកនៅក្នុងកញ្ចប់នោះ ដែលបញ្ជាក់ប្រាប់នូវព័ត៌មានអំពីថ្នាំពេទ្យនេះ មូលហេតុដែលលោកអ្នកកំពុងផ្ញើថ្នាំពេទ្យនេះ ព្រមទាំងបញ្ជាក់ថាថ្នាំពេទ្យនោះគឺសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនលោកអ្នក
- ទុកថ្នាំពេទ្យនេះនៅក្នុងកញ្ចប់ដើមរបស់វា ដើម្បីបង្ហាញយ៉ាងច្បាស់នូវផ្លាកដែលមានឈ្មោះរបស់លោកអ្នក និងការណែនាំអំពីកម្រិតប្រើ
- ភ្ជាប់ទៅនឹងកញ្ចប់របស់លោកអ្នកនូវសេចក្តីប្រកាសដែលសរសេរបំពេញប្រាប់ភ្នាក់ងារគយថាកញ្ចប់នេះមានថ្នាំពេទ្យតាមវេជ្ជបញ្ជា ដែលសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់លោកអ្នក។ ប៉ុស្តិ៍សំបុត្រមានសេចក្តីប្រកាសប្រាប់ភ្នាក់ងារគយ។

ការផ្តល់ថ្នាំពេទ្យ PBS ទៅឲ្យសមាជិកគ្រួសារ ឬមិត្តភក្តិដែលគ្មានវេជ្ជបញ្ជាសំរាប់អ្នកទាំងនោះមិនត្រឹមតែជាអំពើខុសច្បាប់តែប៉ុណ្ណោះទេ វាថែមទាំងអាចបង្កគ្រោះថ្នាក់ដល់សុខភាពរបស់អ្នកទាំងនោះទៀតផង។ វាអាចមានគ្រោះថ្នាក់ក្នុងការប្រើថ្នាំពេទ្យដែលហួសកាលកំណត់ប្រើ ឬថ្នាំពេទ្យដែលមិនបានចេញវេជ្ជបញ្ជាជាក់លាក់សំរាប់លោកអ្នក។

## ដើម្បីទទួលព័ត៌មានបន្ថែម

| | |
|---|---|
| វ៉ិបសាយ | **www.medicareaustralia.gov.au** |
| អ៊ីមែល | **pbs@medicareaustralia.gov.au** |
| ទូរស័ព្ទ | **1800 500 147**** (ព័ត៌មានអំពីការផ្ញើ ឬយកថ្នាំពេទ្យ PBS ទៅបរទេស) |
| | **1800 020 613**** (ទូរស័ព្ទសាកសួរទូទៅអំពី PBS) |
| TTY | **1800 552 152**** (អ្នកមានពិការភាពខាងស្តាប់ និងនិយាយ) |
| TIS | **131 450*** (កិច្ចបំរើបកប្រែភាសា) |

*គិតថ្លៃទូរស័ព្ទ។

**គិតថ្លៃទូរស័ព្ទចេញពីទូរស័ព្ទចល័ត និងទូរស័ព្ទដែលត្រូវបង់ថ្លៃសំរាប់ប្រើប៉ុណ្ណោះ។

1577_12g.04.11.09